ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៩១ . អនក្រ-បក

# អនុក្រឹត្យ

# ស្តីពី

# មគ្គុទ្ទេសក៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារនិងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១១

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីវិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ សម្រាប់បម្រើវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងការគ្រប់គ្រងនិងការអភិវឌ្ឍមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យទទួលបាននូវប្រសិទ្ធភាពនិងគុណភាព
- ធានាឲ្យមានការគោរពតាមក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍
- ចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ ព្រមទាំងធានាដល់ការថែរក្សាធនធានធម្មជាតិ ប្រវត្តិសាស្ត្រ បេតិកភណ្ឌ វប្បធម៌ ប្រពៃណី សិល្បៈ និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ដែលប្រកបវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរនិងអ្នកបកប្រែភាសាមិនត្រូវបានរាប់បញ្ចូលជាមគ្គុទេសក៍ទេសចរណ៍ទេ។

**មាត្រា ៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

មគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់បុគ្គលប្រកបអាជីពជាអ្នកទទួលជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ សំដៅដល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ ជាអាជ្ញាបណ្ណពេញសិទ្ធិឬអាជ្ញាបណ្ណបណ្តោះអាសន្ន។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលត្រូវបានអនុញ្ញាតឲ្យបំពេញការងារនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅគ្រប់គោលដៅទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចណ៍ថ្នាក់តំបន់ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍ តែនៅក្នុងដែនដីនៃរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍ សំដៅដល់មគ្គុទ្ទេសក៍ទេសចរណ៍មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវតែនៅក្នុងសហគមន៍ប៉ុណ្ណោះ។

អ្នកឧទ្ទេសនាម សំដៅដល់បុគ្គលដែលត្រូវបានប្រគល់ភារកិច្ចឲ្យពន្យល់ អធិប្បាយជូនភ្ញៀវនៅតាមប្រាសាទឬតាមសារមន្ទីរ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងទេសចរណ៍ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍។

ក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដល់មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស។

ក្រសួងទេសចរណ៍មានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិនិងថ្នាក់តំបន់ ដល់មគ្គុទ្ទេសក៍ទេសចរណ៍។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិងថ្នាក់សហគមន៍ដល់មគ្គុទ្ទេសក៍ទេសចរណ៍ ដោយមានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាសេនាធិការ។

**មាត្រា ៦.-**

ការគ្រប់គ្រង ការផ្តល់អាជ្ញាបណ្ណ និងការបែងចែកកម្រិតមគ្គុទ្ទេសក៍ទេសចរណ៍ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិនិងថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ៧.-**

ក្រសួងទេសចរណ៍មានសិទ្ធិចាត់តាំងមន្ត្រីជំនាញឲ្យចុះធ្វើអធិការកិច្ចត្រួតពិនិត្យសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍តាមគោលដៅទេសចរណ៍នានានៅក្នុងរាជធានី ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងការធ្វើអធិការកិច្ច មន្ត្រីជំនាញនៃក្រសួងទេសចរណ៍អាចសហការនិងសម្របសម្រួលជាមួយនគរបាលទេសចរណ៍ មន្ត្រីនៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀត។ ទំនាក់ទំនងរវាងមន្ត្រីអធិការកិច្ចទេសចរណ៍និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៣
## វិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍
## ផ្នែកទី១
## អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ៨.-**

លក្ខណវិនិច្ឆ័យសម្រាប់ការពិនិត្យវាយតម្លៃនិងការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានដូចខាងក្រោម៖

ក- ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរនិងមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។

ខ- មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាលត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍។

គ- លិខិតបញ្ជាក់កិរិយាមារយាទ ដែលចេញដោយរដ្ឋបាលឃុំ សង្កាត់ ដែលខ្លួនរស់នៅសម្រាប់ការសុំអាជ្ញាបណ្ណទេសចរណ៍។

ឃ- វិញ្ញាបនបត្រពិនិត្យសុខភាពនិងកាយសម្បទាចេញដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរសុខាភិបាលរាជធានី ខេត្ត ឬមន្ទីរពេទ្យដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនិងមានការឯកភាពពីក្រសួងទេសចរណ៍។

ង- ប្រវត្តិរូបសង្ខេបដែលមានបិទរូបថត។

**មាត្រា ៩.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍រួមមាន៖

- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ
- អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍។

**មាត្រា ១០.-**

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍នៅក្រសួងទេសចរណ៍ឬនៅរដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមប្រភេទនៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍។

ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១១.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មានសុពលភាពអប្បបរមា០១(មួយ)ឆ្នាំ គិតពីថ្ងៃចេញអាជ្ញាបណ្ណ។ សុពលភាពជាក់លាក់នៃអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មិនអាចធ្វើការផ្ទេរឬការលក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គលនិងបទពិសោធរបស់ម្ចាស់អាជ្ញាបណ្ណ។

**មាត្រា ១២.-**

នៅពេលមានការខូចខាតឬការបាត់បង់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរដោយមានមូលហេតុច្បាស់លាស់និងមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតាឡើងវិញក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃដែលខូចខាតឬបាត់បង់។ ក្នុងករណីនេះ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវរាយការណ៍ជាបន្ទាន់ជូនសមត្ថកិច្ចដែលនៅជិតបំផុត អំពីមូលហេតុនៃការខូចខាតឬការបាត់បង់ដើម្បីទទួលបាននូវលិខិតបញ្ជាក់ដឹងឮពីសមត្ថកិច្ចសម្រាប់កាន់តាមខ្លួនពេលធ្វើអាជីវកម្មមុនពេលទទួលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ទុតិយតា។

នៅពេលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវបានលុបឬព្យួរ ឬពេលមគ្គុទ្ទេសក៍ទេសចរណ៍ឈប់ប្រកបអាជីពជាមគ្គុទ្ទេសក៍ទេសចរណ៍ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវប្រគល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជូនក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិវិញ។

## ផ្នែកទី២
## ការប្រតិបត្តិវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៣.-**

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ពីក្រសួងទេសចរណ៍ឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ១៤.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានកាតព្វកិច្ចដូចតទៅ៖

ក- គោរព អនុវត្តឲ្យបានត្រឹមត្រូវនូវក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍

ទេសចរណ៍ព្រមទាំងប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឲ្យបានល្អ។

ខ- ប្រតិបត្តិត្រឹមត្រូវតាមវិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ដោយមិនដើរតួនាទីជាការីទេសចរណ៍ ឬភ្នាក់ងារទេសចរណ៍។

គ- មិនត្រូវទាមទារកម្រៃឬផលប្រយោជន៍ពីអ្នកលក់ឬពីអ្នកផ្តល់សេវាកម្មទេសចរណ៍ផ្សេងៗ។

ឃ- មិនត្រូវធ្វើសកម្មភាពដែលប៉ះពាល់ជាអវិជ្ជមានដល់គោលនយោបាយជាតិលើវិស័យទេសចរណ៍។

ង- ការពារប្រយោជន៍ជាតិនិងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សានិងគ្រប់គ្រងធនធានធម្មជាតិ លម្អបៃតង មិនបំពុលឬមិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្សមរតកវប្បធម៌ ការពារសម្បត្តិវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន។

ច- ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់និងទទួលខុសត្រូវផ្តល់សេវាកម្មដូចដែលបានសន្យាព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ឆ- ប្តឹងឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ ដែលនៅជិតបំផុតក្នុងករណីដឹងឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើស ការជួញដូរវត្ថុបុរាណ និងបទល្មើសបេតិកភណ្ឌ ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាពនិងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងទៀត។

**មាត្រា ១៥.-**

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់អត្តលេខ និងពាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេ សចរណ៍ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

ឯកសណ្ឋានរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៦.-**

មគ្គុទ្ទេសក៍ទេសចរណ៍ណាម្នាក់ដែលគិតថាបានទទួលរងគ្រោះដោយសារសេចក្តីសម្រេចរបស់ក្រ សួងទេសចរណ៍ឬរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបដិសេធ ការព្យួរ ការ[illegible] ការបញ្ចុះថ្នាក់ ឬការសម្រេចដែលមានការពាក់ព័ន្ធផ្សេងៗដូចមានចែងក្នុងមាត្រា២៣ មាត្រា២៤ និងមាត្រា២៥ នៃ

អនុក្រឹត្យនេះ មានសិទ្ធិធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរស្ដីពីការសម្រេចណាមួយដូចរៀបរាប់ខាងលើ។ បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្ដីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ។

**មាត្រា ១៧.-**

ក្រសួងទេសចរណ៍ត្រូវបំផុសនិងជួយរៀបចំបង្កើតសមាគមមគ្គុទ្ទេសក៍ទេសចរណ៍នៅថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ព្រមទាំងបង្កលក្ខណៈឲ្យសមាគមនេះរៀបចំបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវដាក់ឆ្លងសេចក្ដីព្រាងក្រមប្រតិបត្តិវិជ្ជាជីវៈនិងក្រមសីលធម៌វិជ្ជាជីវៈនេះទៅក្រសួងទេសចរណ៍ដើម្បីពិនិត្យនិងយល់ព្រម។

## ផ្នែកទី៣
## ការបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍

**មាត្រា ១៨.-**

ការបណ្ដុះបណ្ដាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស។

មុខវិជ្ជាក្នុងការប្រឡងជ្រើសរើស ដើម្បីទទួលបានការបណ្ដុះបណ្ដាលជាមគ្គុទ្ទេសក៍ទេសចរណ៍ដែលត្រូវតែមានជាការចាំបាច់រួមមាន៖

ក- ភាសាបរទេសមួយ។

ខ- ភូមិសាស្ត្រប្រទេសកម្ពុជា។

គ- ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។

ឃ- ចំណេះដឹងទូទៅអំពីទេសចរណ៍ សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសង្គមរបស់កម្ពុជា។

ក្រសួងទេសចរណ៍អាចបំពេញបន្ថែមមុខវិជ្ជាមួយចំនួនទៀតស្របតាមការចាំបាច់ឬការតម្រូវដែលមានកំណត់ក្នុងផែនការអភិវឌ្ឍទេសចរណ៍។

លក្ខខណ្ឌនិងនីតិវិធីនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ១៩.-**

ក្រសួងទេសចរណ៍អាចធ្វើសហការជាមួយសាលាវិជ្ជាជីវៈទេសចរណ៍រដ្ឋឬឯកជនក្នុងការបណ្ដុះ

បណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍។ ការរៀបចំកម្មវិធីសិក្សានិងគ្រូសម្រាប់ការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានពិនិត្យនិងទទួលស្គាល់ដោយក្រសួងទេសចរណ៍។

**មាត្រា ២០.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំផែនការជ្រើសរើស ការបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ស្របតាមផែនការអភិវឌ្ឍទេសចរណ៍។

គម្រោងការងារជ្រើសរើស ការបណ្តុះបណ្តាល និងវិក្រឹតការមគ្គុទ្ទេសក៍ទេសចរណ៍ ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២១.-**

ក្រសួងទេសចរណ៍អាចអនុញ្ញាតឲ្យមានអ្នកបកប្រែភាសាបំពេញភារកិច្ចជាមួយនឹងមគ្គុទ្ទេសក៍ទេសចរណ៍បាន ដើម្បីដោះស្រាយជាបណ្តោះអាសន្ននូវបញ្ហាមគ្គុទ្ទេសក៍ទេសចរណ៍ដែលពុំចេះភាសារបស់ភ្ញៀវ។

ការគ្រប់គ្រងអ្នកបកប្រែភាសា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២២.-**

អ្នកឧទ្ទេសនាមតាមប្រាសាទឬតាមសារមន្ទីរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួង ឬស្ថាប័នសាមីដោយមានកិច្ចសហការជាមួយក្រសួងទេសចរណ៍ក្នុងការបណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ចនិងទេសចរណ៍។

មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវបានទទួលស្គាល់ជាមគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសដោយមានវិញ្ញាបនបត្រជំនាញដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នសាមី។ មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេសនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញការងារបន្ថែមនៅតាមប្រាសាទឬតាមសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិឬថ្នាក់ពិភពលោក។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា ២៣.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការលុបចោលអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ណាដែលត្រូវបានតុលាការសម្រេចជាស្ថាពរថាមានទោសពីបទឧក្រិដ្ឋឬពីបទមជ្ឈិម។

**មាត្រា ២៤.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើការព្យួរអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ជាបន្ទាន់ ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍មានបញ្ហាកាយសម្បទាឬអសមត្ថភាពផ្នែកបញ្ញាសម្បទា ឬមានជំងឺឆ្លងធ្ងន់ធ្ងរដែលមានលក្ខណៈអាចប៉ះពាល់ដល់សុខភាពទេសចរក្នុងរយៈពេលសុពលភាពនៃអាជ្ញាបណ្ណ។

**មាត្រា ២៥.-**

ក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ក្នុងករណីដែលមគ្គុទ្ទេសក៍ទេសចរណ៍បានផ្តល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំ ឬខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ។ ក្នុងករណីនេះក្រសួងទេសចរណ៍ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ៣០(សាមសិប)ថ្ងៃជាមុន ទៅកាន់ម្ចាស់អាជ្ញាបណ្ណ និងត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់។

**មាត្រា ២៦.-**

លក្ខខណ្ឌនិងនីតិវិធីនៃការលុប ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា ២៧.-**

ការលុបចោល ការព្យួរ ឬការបញ្ចុះថ្នាក់អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ឬការពិន័យអន្តរការណ៍មិនធ្វើឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ដែលប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវរដ្ឋប្បវេណីនិង/ឬការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

**មាត្រា ២៨.-**

បុគ្គលណាដែលប្រកបអាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ស្របតាមមាត្រា៦៥នៃច្បាប់ស្តីពីទេសចរណ៍។

**មាត្រា ២៩.-**

ជនណាដែលក្លែងអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ឬឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

## ជំពូកទី៦

## អន្តរប្បញ្ញត្តិ

**មាត្រា ៣០.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញដោយក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍ រាជធានី ខេត្ត កន្លងមកដែលនៅមានសុពលភាព ត្រូវនៅបន្តអនុវត្តរហូតដល់អស់សុពលភាព។

មគ្គុទ្ទេសក៍ទេសចរណ៍ដែលមានបំណងប្រកបអាជីវកម្មជាមគ្គុទ្ទេសក៍ទេសចរណ៍បន្តទៀត ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីទេសចរណ៍និងអនុក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ